# សារៈសំខាន់នៃការផ្សព្វផ្សាយកិច្ចដំណើរការជម្រះក្តីរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម

**(ចាន ប្រាថ្នា : ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១២)**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺជាតុលាការអន្តរជាតូនីយកម្មដែលត្រូវបានបង្កើតឡើងដោយកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាតិ ដើម្បីជំនុំជម្រះទោសលើមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានកើតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ តុលាការនេះអនុវត្តទាំងច្បាប់ជាតិ និងអន្តរជាតិ ព្រមទាំងមានការចូលរួមពីសំណាក់អង្គការសហប្រជាតិ ដើម្បីធានានូវឯករាជ្យភាពរបស់តុលាការក្នុងការសម្រេចសេចក្តីប្រកបដោយត្រឹមត្រូវ និងយុត្តិធម៌ ។ តុលាការនេះត្រូវបានបង្កើតឡើងក្នុងគោលបំណងស្វែងរកយុត្តិធម៌ជូនជនរងគ្រោះដែលបានស្លាប់ និងអ្នករស់រានមានជីវិតពីអំពើឧក្រិដ្ឋកម្មដែលបានកើតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ជាងនេះទៅទៀត អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នឹងក្លាយជាគំរូសម្រាប់តុលាការកម្ពុជាក្នុងដំណើរការស្វែងរកយុត្តិធម៌នៅប្រទេសកម្ពុជា និងធ្វើឲ្យមានភាពប្រសើរឡើងនូវវិធានច្បាប់ដែលមានស្រាប់ ដើម្បីជំរុញឲ្យក្លាយជាប្រទេសនីតិរដ្ឋពេញលេញ ។

បច្ចុប្បន្នអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា កំពុងតែដំណើរការជំនុំជម្រះទោសលើអតីតមេដឹកនាំជាន់ខ្ពស់របស់បក្សកុម្មុយនិស្តកម្ពុជា ដែលគ្រប់គ្រងប្រទេសនាំឲ្យប្រជាជនស្លាប់ជាង ២លាននាក់ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ នេះគឺជាសំណុំរឿងប្រវត្តិសាស្ត្រ ដែលនឹងត្រូវលាតត្រដាងឲ្យប្រជាជនកម្ពុជា និងសហគមន៍អន្តរជាតិ ដឹងអំពីមូលហេតុពិតប្រាកដដែលនាំឲ្យប្រជាជនកម្ពុជាស្លាប់ដ៏ច្រើនសន្ធឹកសន្ធាប់ដោយសារអំពើអមនុស្សធម៌ និងការកាប់សម្លាប់ដ៏សាហាវឃោរឃៅនៅក្នុងរបបនេះ ។

**ដូច្នេះ** ការផ្សព្វផ្សាយអំពីកិច្ចដំណើរការជំនុំជម្រះក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឲ្យបានទូលំទូលាយ គឺជាកត្តាសំខាន់ និងចាំបាច់ដែលត្រូវតែធ្វើ ។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម គប្បីទទួលបានព័ត៌មានគ្រប់គ្រាន់អំពីមូលហេតុពិតប្រាកដនៃអំពើឧក្រិដ្ឋកម្មដែលខ្លួនបានឆ្លងកាត់ ។ ការផ្សព្វផ្សាយនេះដែរ នឹងបង្កើនការយល់ដឹងអំពីរបបខ្មែរក្រហម ដែលជួយជំរុញបន្ថែមឲ្យសម្រេចបាននូវគោលបំណងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការបញ្ជ្រៀបការយល់ដឹង អំពីរបបកម្ពុជាប្រជាធិបតេយ្យដល់កូនខ្មែរជំនាន់ក្រោយ ។ បន្ថែមលើនេះទៀត ការផ្សព្វផ្សាយអំពីកិច្ចដំណើរការជំនុំជម្រះរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺអាចជួយបង្កើនការយល់ដឹងដល់ប្រជាជនកម្ពុជាអំពីវិស័យច្បាប់ទាក់ទងនឹងសិទ្ធិទទួលបានការកាត់ក្តីប្រកបដោយត្រឹមត្រូវ និងយុត្តិធម៌ ។ ចំណេះដឹងនេះនឹងឆ្លើយ

តបសំណួរមួយចំនួនដែលតែងតែចោទសួរថា« ប្រជាជនកម្ពុជា អ្នកណាៗក៏ដឹងថារបបខ្មែរក្រហម គឺជារបបសាហាវយង់ឃ្នង សម្លាប់មនុស្សជាច្រើន ។ ហេតុអ្វីចាំបាច់មានការរកភស្តុតាងច្រើន និងប្រើរយៈពេលយូរម្លេះក្នុងការជម្រះក្តីមេដឹកនាំទាំងនោះ? ហេតុអ្វីតុលាការចាំបាច់គោរពសិទ្ធិរបស់ជនជាប់ចោទទាំងនោះច្រើនម្លេះ ព្រោះមេដឹកនាំទាំងនោះមិនដែលគោរពសិទ្ធិរបស់ប្រជាជនកម្ពុជាឡើយ?...» ។ ទាំងនេះគឺជាសំណួរសាមញ្ញដែលប្រជាជនកម្ពុជាមួយចំនួនតែងតែចោទសួរ ប៉ុន្តែទាមទារឲ្យមានការបកស្រាយ ឬផ្សព្វផ្សាយឲ្យបានច្បាស់លាស់ និងទូលំទូលាយ បើពុំនោះសោត គំនិតជាអវិជ្ជមានរបស់គាត់មកលើកិច្ចដំណើរការជំនុំជម្រះក្តីរបស់តុលាការក្នុងការស្វែងរកយុត្តិធម៌ នឹងកើតមានជាមិនខាន ។ ការណ៍ដែលជនរងគ្រោះយល់ដឹងអំពីការពិតនៃអំពើដែលខ្លួនបានទទួលរង និងកិច្ចដំណើរការក្នុងការស្វែងរកយុត្តិធម៌ គឺជាកត្តាសំខាន់ដែលជំរុញឲ្យមានការផ្សះផ្សាជាតិ ។

ដោយមើលឃើញពីអត្ថប្រយោជន៍ដ៏ច្រើនសន្ធឹកសន្ធាប់សម្រាប់ប្រជាជនកម្ពុជា ដែលកើតចេញពីកិច្ចដំណើរការជំនុំជម្រះក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ទើបមជ្ឈមណ្ឌលឯកសារកម្ពុជាខិតខំប្រឹងប្រែងរួមចំណែកក្នុងការផ្សព្វផ្សាយព័ត៌មានទាំងនេះឲ្យបានច្រើនបំផុត តាមលទ្ធភាពដែលអាចធ្វើបាន ។ បច្ចុប្បន្នមន្ត្រីកិច្ចការសាធារណៈរបស់តុលាការបានខិតខំប្រឹងប្រែងផ្សព្វផ្សាយកិច្ចដំណើរការជំនុំជម្រះក្តីរបស់តុលាការ តាមរយៈការនាំយកប្រជាជនកម្ពុជាមួយចំនួន ឲ្យមកចូលរួមទស្សនាសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ ។ ទន្ទឹមគ្នានេះដែរ មជ្ឈមណ្ឌលឯកសារកម្ពុជា «**បាន**» និង «**កំពុងបន្ត**» ផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងការជំនុំជម្រះក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ទៅដល់ប្រជាជននៅតាមមូលដ្ឋាន ឬសាកលវិទ្យាល័យផ្សេងៗ នៅក្នុងប្រទេសកម្ពុជា ។ គួររំពឹកថានៅពេលថ្មីៗនេះ (ថ្ងៃទី៦ ខែ កក្កដា ឆ្នាំ២០១២) មជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំសិក្ខាសាលានៅសកលវិទ្យាល័យបាត់ដំបង ដែលមានចម្ងាយ ២៩១ គីឡូម៉ែត្រពីរាជធានីភ្នំពេញ ។ សិក្ខាសាលានេះអនុញ្ញាតឲ្យអ្នកចូលរួម មានឱកាសចោទសំណួរ និងផ្តល់យោបល់ទាក់ទងនឹងកិច្ចដំណើរការជំនុំជម្រះក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ក្នុងអំឡុងពេលនោះដែរ មជ្ឈមណ្ឌលបានចែកសៀវភៅព្រឹត្តបត្រសង្ខេបការណ៍ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហមចំនួន៧០០ច្បាប់ និងសៀវភៅផ្សេងៗទៀត ជូនអ្នកចូលរួមដើម្បីសិក្សាស្រាវជ្រាវបន្ថែម ។

ចប់